# សេចក្តីសម្រេចលេខ ១៣៦ ស.ស.រ

### ស្តីពី លក្ខខណ្ឌ នៃការផ្តល់លិខិតឆ្លងដែនការទូតចំពោះកម្មាភិបាល

### ចេញទៅបំពេញបេសកកម្មនៅ បរទេស

# ក្រុមប្រឹក្សារដ្ឋមន្ត្រី

-បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៣ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២ របស់ក្រុមប្រឹក្សារដ្ឋ ។

-ផ្អែកតាមសភាពការណ៍រីកចម្រើនរបស់បដិវត្តកម្ពុជា នាពេលបច្ចុប្បន្ន ។

-តាមសំណើ របស់ក្រសួងការបរទេស ។

**<u>សម្រេច</u>**

**ប្រការ ១** លិខិតឆ្លងដែន ទូតអាចផ្តល់ជូនបានចំពោះកម្មាភិបាលដូចខាងក្រោម ៖

-អគ្គលេខាគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តកម្ពុជា

-សមាជិកការិយាល័យនយោបាយ នៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តកម្ពុជា

-សមាជិកគណៈលេខាមជ្ឈិមបក្ស

-សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស

-ប្រធាន អនុប្រធានស្ថាប័នបក្ស ចំណុះមជ្ឈិមបក្ស

-ប្រធាន អនុប្រធានអគ្គលេខាធិការ និងសមាជិកក្រុមប្រឹក្សារដ្ឋ

-ប្រធាន អនុប្រធាន ក្រុមប្រឹក្សារដ្ឋមន្ត្រី

-ប្រធាន អនុប្រធាន និងអគ្គលេខាធិការរដ្ឋសភា

-រដ្ឋមន្ត្រី អនុរដ្ឋមន្ត្រី ឧបការីរដ្ឋមន្ត្រី និងថ្នាក់ប្រហាក់ប្រហែល

-ប្រធាន អនុប្រធានតុលាការកំពូល

-អគ្គរដ្ឋអាជ្ញា អគ្គរដ្ឋអាជ្ញារង

-ប្រធាន អនុប្រធាន និងអគ្គលេខាធិការមជ្ឈិមរណសិរ្ស

-ប្រធាន អនុប្រធាន សមាគមយុវជនបដិវត្តមជ្ឈិម សមាគមនារីមជ្ឈិម

-លេខា អនុលេខាអចិន្ត្រៃយ៍សម្ព័ន្ធយុវជន ប្រជាជនបដិវត្តកម្ពុជា

-លេខា អនុលេខាគណៈកម្មាធិការបក្សខេត្ត-ក្រុង

-ប្រធាន អនុប្រធានអគ្គនាយកដ្ឋាន

-និពន្ធនាយក-និពន្ធនាយករងកាសែតប្រជាជន និងកាសែតកម្ពុជា

-ប្រធាន អនុប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង

-ប្រធាន អនុប្រធានបណ្តាអគ្គចំណុះក្រសួងការពារប្រទេស

-ប្រធាន អនុប្រធានតំបន់

-ប្រធានកងពលធំ

-សមាជិកសភាជាតិ ដែលចេញទៅបរទេស ក្នុងតួនាទីជាសមាជិកសភា ដើម្បីបំពេញកិច្ចការក្នុងនាមសភាជាតិ ។

-សមាជិកមជ្ឈិមរណសិរ្សចេញទៅបរទេសជាតំណាងអោយរណសិរ្សនិងក្នុងបេសកកម្មជាផ្លូវការ។

-ប្រធាន អនុប្រធានរាល់គណៈប្រតិភូបក្ស រដ្ឋ រដ្ឋាភិបាល និងអង្គការមហាជនមជ្ឈិមដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋានឡើង ហើយដែលត្រូវបានចាត់តាំងអោយចេញទៅប្រទេសក្រៅ ដើម្បីធ្វើការចរចាចុះហត្ថលេខា ឬ ចូលរួមសន្និសីទអន្តរជាតិ ។

-ឯកអគ្គរដ្ឋទូត បេសកជន តំណាងអចិន្ត្រៃយ៍ ទីប្រឹក្សា លេខាធិការស្ថានទូត អនុព័ន្ធស្ថានទូត នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រចាំប្រទេសក្រៅ ។

-អគ្គកុងស៊ុល កុងស៊ុង អនុកុងស៊ុល ។

-ប្រធាន អនុប្រធាននាយកដ្ឋាន នៃក្រសួងការបរទេស និងគណៈទាក់ទងបរទេសមជ្ឈិមបក្ស ។

-តំណាងពាណិជ្ជកម្មប្រចាំជាអចិន្ត្រៃយ៍ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រចាំនៅប្រទេសក្រៅ ។

-អ្នកនាំសារការទូត ។

**ប្រការ ២** ភរិយាធ្វើដំណើររួមជាមួយប្តីទៅបរទេស ត្រូវបានទទួលលិខិតឆ្លងដែនដូចប្តី ។

-ភរិយាធ្វើដំណើរ ក្នុងនាមជាភរិយាអ្នកការទូត ត្រូវកាន់លិខិតឆ្លងដែនការទូត

-កូនអ្នកការទូត ប្រុស អាយុត្រឹម ១៦ ឆ្នាំ ចុះ និងកូនស្រីមិនទាន់រៀបការធ្វើដំណើរជាមួយឪពុកម្តាយត្រូវកាន់លិខិតឆ្លងដែនដូច ឪពុកម្តាយ ។

-កូនប្រុស អាយុលើសពី ១៦ឆ្នាំ និង កូនស្រីរៀបការហើយ ត្រូវកាន់លិខិតឆ្លងដែនផ្លូវការ ។

-ភរិយាពីថ្នាក់សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងពីរដ្ឋមន្ត្រីឡើង កាន់លិខិតឆ្លងដែនការទូត ។ ចំពោះកូន គឺប្រើគោលការណ៍ខាងលើ ។

**ប្រការ ៣** កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលត្រូវបានទទួលការអនុញ្ញាតធ្វើ វិក្រឹតការរយៈពេលវែងទៅព្យាបាលជម្ងឺនៅឯបរទេស ត្រូវទទួលលិខិតឆ្លងដែនផ្លូវការ ។

កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលត្រូវចាត់អោយទៅរៀនរយៈពេលវែង ត្រូវទទួលលិខិតឆ្លងដែនធម្មតា ។

**ប្រការ ៤** ចំពោះករណីផ្សេងទៀត ក្រសួងការបរទេសពិនិត្យ និងសម្រេចចេញបណ្តាលិខិតឆ្លងដែនណាដែលសមស្រប និង ឋានៈនិងលក្ខណៈ បេសកកម្មរបស់បុគ្គលម្នាក់ ។

**ប្រការ ៥** សេចក្តីសម្រេចលេខ ១៧៤ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៨០ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦** ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងការបរទេស ក្រសួងមហាផ្ទៃ និងបណ្តាក្រសួងដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ

ធ្វើនៅភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៨៦

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**